**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**

លេខ: ០១៧/០២១ អអរ

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

ព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តព្រះសីហនុ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ជាម ហ៊ីម ប្រធានក្រុមប្រឹក្សាខេត្ត និងប្រតិភូខេត្តព្រះសីហនុ**
- **លោក អ៊ី សុខឡេង អភិបាលក្រុងព្រះសីហនុ**
- **លោក ភាន់ ឡឿង ចៅសង្កាត់លេខ៣**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្ដីផ្ដើម

ថ្នាក់ដឹកនាំខេត្តព្រះសីហនុ មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត មានជីវភាពធូធារតាមរយៈកិច្ចការសំខាន់ៗ ដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំ ការអនុវត្តតួនាទី ភារកិច្ច ស្របតាមជំនាញ និងបទពិសោធន៍ ការផ្លាស់ប្ដូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដែលឈានទៅរកការផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍន៍ប្រកបដោយដោយសមធម៌ និងចីរភាព។

### II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

❖ ក្រុមប្រឹក្សាខេត្ត

- បានប្រជុំទៀងទាត់ស្របតាមប្រតិទិនស្តីពីកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ការអនុវត្តតាមបទបញ្ជាផ្ទៃ ក្នុងដោយសង្កេតឃើញថា ពីកិច្ចប្រជុំមួយទៅកិច្ចប្រជុំមួយមានការរីកចម្រើនលើការពិភាក្សាយ៉ាងផុលផុសលើវឌ្ឍនភាពការងាររបស់រដ្ឋបាលខេត្ត តាមរយៈការត្រួតពិនិត្យលើរបាយការណ៍ប្រចាំខែ និងការឆ្លើយបំភ្លឺជូនអង្គប្រជុំពីបណ្តាមន្ទីរ អង្គភាពជំនាញ និងអ្នកពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវ។
- មានការរៀបចំកិច្ចប្រជុំសម្ងាត់ដើម្បីវាយតម្លៃការតែងតាំង ផ្លាស់ប្តូរ មុខតំណែងមន្ត្រី ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងប្រកបដោយយុត្តិធម៌។
- ក្រុមប្រឹក្សាខេត្តបានរៀបចំបែងចែកការទទួលខុសត្រូវលើកិច្ចប្រតិបត្តិការ ដែលជួយសម្រួលដល់ការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនសម្រាប់ចុះមូលដ្ឋាន។
- សមាជិកក្រុមប្រឹក្សា បានចូលរួមសកម្មភាពនានា ទាំងសកម្មភាពអភិវឌ្ឍន៍ សកម្មភាពសង្គម និងសកម្មភាពផ្នែកសាសនា ជាមួយថ្នាក់ដឹកនាំខេត្ត និងបានចែករំលែកព័ត៌មានដល់សមាជិកនានាក្នុងជួរក្រុមប្រឹក្សា។
- បានរៀបចំបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើស ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋថ្នាក់ខេត្ត ស្របតាមខ្លឹមសារអនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។
- កិច្ចការទំនាក់ទំនងរវាងគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តមានភាពល្អូន មិនតែប៉ុណ្ណោះទំនាក់ទំនងរវាងមន្ទីរ/ អង្គភាពជំនាញជាមួយក្រុមប្រឹក្សាខេត្ត ក៏មានភាពល្អប្រសើរ ដោយក្រុមប្រឹក្សាបានអញ្ជើញតំណាងស្ថាប័នទាំងនេះមកចូលរួមប្រជុំទៀងទាត់ ដើម្បីរាយការណ៍។
- ការគ្រោងថវិកាប្រចាំឆ្នាំ ត្រូវបានពិភាក្សាក្នុងក្រុមការងារ ដែលមានតំណាងក្រុមប្រឹក្សាចូលរួម និងបានជជែកដេញដោល ដើម្បីសម្រេចទៅលើថវិកាគុណប្រយោជន៍ខេត្តឱ្យចំគោលដៅ និងប្រកបដោយសមធម៌រវាងក្រុងទាំង២ និងស្រុកទាំង៣ ឱ្យមានតុល្យភាពរវាងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត។

❖ ក្រុងព្រះសីហនុ

- ការចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ៖ បានដាក់កម្លាំងគណៈបញ្ជាការឯកភាពចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ នៅតាមគោលដៅផ្លូវសំខាន់ៗ នៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុបានចំនួន ១៤លើក។
- បានដាក់កម្លាំងប្រចាំការ ២៤ម៉ោង នៅតាមគោលដៅដែលមានប្រជាពលរដ្ឋរស់នៅច្រើន កន្លែងរមណីយដ្ឋានតាមតំបន់ឆ្នេរ ផ្សារ កន្លែងអាជីវកម្ម និងតាមបណ្តាផ្លូវដែលមានចរាចរណ៍ច្រើន ដើម្បីពង្រឹងសន្តិសុខ បង្ការទប់ស្កាត់ការកើតមានបទល្មើស និងបង្ក្រាបបទល្មើសឱ្យទាន់ពេលវេលា។

- ការផ្តល់សេវាសាធារណៈ៖ ការិយាល័យច្រកចេញ-ចូលតែមួយនៃរដ្ឋបាលក្រុងព្រះសីហនុ បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋសរុបចំនួន ២៧.៦២៣សេវា សរុបជាទឹកប្រាក់ចំនួន ២៧៦.២៧៦.០០០រៀល នៃគម្រោងផែនការឆ្នាំ២០២០ចំនួន ៩០០.៤៣០.០០០រៀល។ បើធៀបនឹងឆ្នាំ២០១៩ សេវាមានការកើនឡើង ២% ស្មើនឹងទឹកប្រាក់គិតជាភាគរយថយចុះចំនួន ៧២% ដោយសារសេវានីត្យានុកូលកម្មកើនឡើងច្រើន ប៉ុន្តែសេវាផ្សេងៗទៀត មានការថយចុះច្រើនជាងមុន។

❖ **សង្កាត់លេខ៣ នៃក្រុងព្រះសីហនុ**

- ការងារសម្រុះសម្រួលវិវាទ្យវេណី៖ គិតចាប់ពីខែមករា រហូតដល់ខែធ្នូ ឆ្នាំ២០២០ បានទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ចំនួន ១៦៦ ករណីក្នុងនោះ បានដោះស្រាយរួចជាស្ថាពរ ចំនួន ១៣០ ករណី, បានសម្របសម្រួល និងដកពាក្យបណ្តឹងចំនួន ២៦ ករណី, សាមីខ្លួនមិនចូលខ្លួនដោះស្រាយ ចំនួន ០៧ ករណី, បានបញ្ជូនទៅសាលាក្រុងព្រះសីហនុ ចំនួន ០៣ ករណី។
- ការងារអភិវឌ្ឍ៖
  - បានសាងសង់ផ្លូវបេតុងអាមេប្រវែង ២៧៥ ម៉ែត្រ ទទឹង ៥ម៉ែត្រ កម្រាស់ ០.១៥ ម៉ែត្រទីតាំងភូមិ២ សង្កាត់លេខ៣ ប្រើប្រាស់ថវិកាចំនួន ១១៨,៧១៨,២៨៥ រៀល (មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០១៨)។
  - បានសាងសង់ផ្លូវបេតុងអាមេប្រវែង ១៦២ ម៉ែត្រ ទទឹង ៦ ម៉ែត្រ កម្រាស់ ០.១៥ ម៉ែត្រ ទីតាំងភូមិ១ សង្កាត់លេខ៣ ប្រើប្រាស់ថវិកាចំនួន ១៤៧,៩៣៩,៦២៣ រៀល(មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០១៩)។
  - បានសាងសង់ផ្លូវបេតុងអាមេប្រវែង ៥២០ ម៉ែត្រ ទទឹង ៦ ម៉ែត្រ កម្រាស់ ០.២០ ម៉ែត្រ ទីតាំងភូមិ៣ សង្កាត់លេខ៣ ប្រើប្រាស់ថវិកាចំនួន ៣០៦,៩៦៧,៧៤២ រៀល(មូលនិធិអភិវឌ្ឍន៍ឆ្នាំ២០២០)។
  - បានជួសជុលផ្លូវលេខ១២០ ដោយចាក់បេតុងប្រវែង ១៤៦ ម៉ែត្រ ទទឹង ៦ ម៉ែត្រ និងស្ពានជាឡូ ៣ ម៉ែត្រ ២ប្រឡោះមួយកន្លែងប្រវែង ២១ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ប្រើប្រាស់ថវិកាចំនួន ៧៩៦,១២០,០០០រៀល ទីតាំងភូមិ២ សង្កាត់លេខ៣។
  - ការស្តាបនាផ្លូវរបស់រាជរដ្ឋាភិបាល ចំនួន ៣៤ ខ្សែ ក្នុងនោះពាក់ព័ន្ធ និងសង្កាត់លេខ៣ មាន៩ខ្សែ។
  - ការងារសាងសង់សំណង់ វិនិយោគ៖ ការដ្ឋានសំណង់គិតចាប់ពីឆ្នាំ ២០១៨ - ២០២០ មានចំនួន ៣៣៧ ការដ្ឋានសំណង់ សណ្ឋាគារ និងកាស៊ីណូមានចំនួន ៧ កន្លែង, កាស៊ីណូ មានចំនួន ៩ កន្លែង, សណ្ឋាគារ មានចំនួន ១៩ កន្លែង, ផ្ទះសំណាក់ មានចំនួន ១១ កន្លែង។

- ការងារសន្តិសុខសណ្តាប់ធ្នាប់ និងការងារភូមិឃុំមានសុវត្ថិភាពៈ រដ្ឋាភិបាលសង្កាត់បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋ ដើម្បីការពារសុវត្ថិភាពភូមិដ្ឋានរបស់យើងគ្រប់ៗគ្នា ក្នុងនោះមានកម្លាំងប្រជាការពារ ចំនួន ១៦២ នាក់ ស្រី ០៣ នាក់ មានគោលដៅប្រចាំការពេលយប់ ចំនួន ០៤គោលដៅ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់លេខ៣ជាប្រចាំ។

## III. ទិសដៅការងារបន្ត

❖ **ក្រុមប្រឹក្សាខេត្ត**

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋាន ដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា។
- បន្តការគាំទ្រក្នុងការអនុវត្តមុខងារ ដែលបានប្រគល់ដោយក្រសួងស្ថាប័ន ថ្នាក់ជាតិ។
- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ ដើម្បីបង្កើតសេវាសាធារណៈឱ្យកៀកនឹងប្រជាពលរដ្ឋមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសមស្របទៅតម្រូវការក្នុងការអភិវឌ្ឍ។
- បន្តការរៀបចំ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ឱ្យទាន់ពេលវេលា និងការរៀបចំផែនការថវិកាប្រចាំឆ្នាំ។
- ពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តិនានា និងបែងចែកភារកិច្ចចូលរួមគាំទ្រការងារពេលការចេញសេចក្តីសម្រេច របស់អង្គប្រជុំក្រុមប្រឹក្សា។
- បន្តការគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងតាមរយៈការិយាល័យប្រជាពលរដ្ឋ។
- ពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា និង គណៈអភិបាល និងគាំទ្រក្នុងការកៀរគរធនធានដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន។
- រៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ក្នុងការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឱ្យបានទៀងទាត់។

- ជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិឃុំ មានសុវត្ថិភាព។
- បន្តការគាំទ្រយន្តការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពដល់រដ្ឋបាលខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់។

❖ **ក្រុងព្រះសីហនុ៖**

- បន្តអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពសង្គមបានកាន់តែល្អប្រសើរ បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងក្រុង។
- បន្តលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ឱ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ។
- បន្តកែលម្អការផ្តល់សេវាសាធារណៈ កាត់បន្ថយអំពើពុករលួយ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនា។

❖ **សង្កាត់លេខ៣៖**

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាល ជូនប្រជាពលរដ្ឋឱ្យលឿន រហ័ស និងមិនរើសអើង។
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ជាប្រចាំ។
- បន្តការចុះពង្រឹងការរៀបចំសណ្តាប់ធ្នាប់ក្នុងមូលដ្ឋានរៀងរាល់ថ្ងៃ។
- បន្តការផ្សព្វផ្សាយពីវិធានការការពារការឆ្លងវីរុសកូវីដ-១៩។
- បន្តការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យយល់ដឹងពីការរស់នៅស្អាត ហូបស្អាតនិងធ្វើអនាម័យបរិស្ថាន។
- ការគៀងគរដៃគូរ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍនៅក្នុងមូលដ្ឋាន។

ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១